ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ :..៤០៤.....អទស

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលសមាសភាពក្រុមការងារដាំស្តារព្រៃលិចទឹកឡើងវិញនៅខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប

រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
និងជា ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- យោងលិខិតលេខ ៦៩៦ សជណ.កធ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងសេចក្តីសម្រេចលេខ ៦២១ អទស ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការបង្កើតក្រុមការងារដាំស្តារព្រៃលិចទឹកឡើងវិញនៅខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរទន្លេសាប

សម្រេច

ប្រការ ១._

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារដាំស្តារព្រៃលិចទឹកឡើងវិញនៅខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប ដែលមានសមាសភាពដូចខាងក្រោម ៖

១-	ឯកឧត្តម	**ហ៊ែល តូនី**	អនុប្រធានក្តាប់រួម អាជ្ញាធរទន្លេសាប	ប្រធាន
២-	ឯកឧត្តម	**សរ គឹមសាន្ត**	អគ្គលេខាធិការ អាជ្ញាធរទន្លេសាប	អនុប្រធាន
៣-	ឯកឧត្តម	**ខូវ ហាស**	អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប	អនុប្រធាន
៤-	លោក	**ឃុក សីលា**	ប្រធាននាយកដ្ឋាន	សមាជិក
៥-	លោក	**ទិន ប៊ុនភៅ**	ប្រធាននាយកដ្ឋាន	សមាជិក

៦-	លោក	ប៉ុន	ភុឌ្ឍី	អនុប្រធាននាយកដ្ឋាន	សមាជិក
៧-	លោក	ហេង	បូរាណ	អនុប្រធាននាយកដ្ឋាន	សមាជិក
៨-	លោកស្រី	ប្រាក់	ចាន់ទឌ្ឍនា	អនុប្រធាននាយកដ្ឋាន	សមាជិក
៩-	លោក	ខូវ	វេចសុខ	ប្រធានការិយាល័យ	សមាជិក
១០-	លោក	សុខ	វ៉ាយ៉ុង	ប្រធានការិយាល័យ	សមាជិក
១១-	លោក	អ៊ូ	ឆួច	ប្រធានការិយាល័យ	សមាជិក
១២-	លោក	ម៉ម	សុធា	ប្រធានការិយាល័យ	សមាជិក
១៣-	លោក	ឈួញ	ណារិទ្ធ	ប្រធានការិយាល័យ	សមាជិក
១៤-	លោក	ម៉ុក	គង្គារ	អនុប្រធានការិយាល័យ	សមាជិក
១៥-	លោក	ឃាន	ច័ន្ទតារា	អនុប្រធានការិយាល័យ	សមាជិក
១៦-	លោក	ជួង	សុវណ្ណគីរី	អនុប្រធានការិយាល័យ	សមាជិក
១៧-	លោក	ខែម	សុវណ្ណឌី	អនុប្រធានការិយាល័យ	សមាជិក

ប្រការ ២._

ក្រុមការងារមានភារកិច្ច ដូចខាងក្រោម ៖

- សិក្សា ប្រមូលចងក្រង និងវិភាគព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងទំហំផ្ទៃដីព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប
- រៀបចំផែនការសកម្មភាពការងារ និងផែនទីពាក់ព័ន្ធ សម្រាប់ដាំស្តារព្រៃលិចទឹក(តំបន់៣) ឡើងវិញ ក្នុងតំបន់ទន្ទ្រាន និងរបេះរឹល ស្ថិតក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប
- ទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីប្រឹក្សាយោបល់ និងចរចាកញ្ចប់ថវិកាជាតិសម្រាប់ប្រើប្រាស់ក្នុងការដាំស្តារព្រៃលិចទឹកឡើងវិញនៅតំបន់បឹងទន្លេសាប
- ទំនាក់ទំនង និងកៀរគរថវិកាពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងកាតព្វកិច្ចពាក់ព័ន្ធ សម្រាប់ដាំស្តារព្រៃលិចទឹកឡើងវិញនៅតំបន់បឹងទន្លេសាប
- សហការ និងសម្របសម្រួលជាមួយបណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ដើម្បីដាំស្តារព្រៃលិចទឹកឡើងវិញនៅតំបន់បឹងទន្លេសាប
- រៀបចំរបាយការណ៍វឌ្ឍនភាពអនុវត្តការងារជូន ឯកឧត្តមប្រធាន ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ណែនាំ
- បំពេញភារកិច្ចផ្សេងៗទៀតដែល ឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន។

ប្រការ ៣._

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាប ឱ្យជួយការងារតាមការចាំបាច់។

ប្រការ ៤._

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៥._

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ទីប្រឹក្សា គ្រប់ប្រធាននាយកដ្ឋានចំណុះឱ្យអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០២៦

រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
និងជា ប្រធានអាជ្ញាធរទន្លេសាប

ជា ដេជ្ជា

ចម្លងជូន ៖
-ក្រសួងធនធានទឹក និងឧតុនិយម
-ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ